# របាយការណ៍ប្រចាំត្រីមាសទី១

(ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣)

## ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (លានរៀល) | ត្រីមាសទី១ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
|---|---|---|
| ទ្រព្យសកម្មសរុប | ៤.០៦៤.៤៤៥ | ៤.០៤៣.៥៣០ |
| បំណុលសរុប | ៣.២៥០.២០៩ | ៣.២៣៨.០៣៨ |
| មូលធនសរុប | ៨១៤.២៣៦ | ៨០៥.៤៩២ |
| **លទ្ធផលហិរញ្ញវត្ថុ (លានរៀល)** | **ត្រីមាសទី១ឆ្នាំ២០២៣** | **ត្រីមាសទី១ឆ្នាំ២០២២** |
| ចំណូលសរុប | ៨៤.៩៥៦ | ៧៨.៦១០ |
| ចំណេញ(ខាត)មុនបង់ពន្ធ | ២៧.០៧៨ | ៣៤.៦៧៧ |
| ចំណេញ(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ | ២១.២២៦ | ២៧.៧៣៩ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ១៨.៤៧៨ | ២៥.៩២៦ |
| **អនុបាតហិរញ្ញវត្ថុ(%)** | **ត្រីមាសទី១ឆ្នាំ២០២៣** | **ឆ្នាំ២០២២** |
| អនុបាតសាធនភាព ❶ | ២២,៣៥ | ២១,៨១ |
| អនុបាតបំណុលធៀបនឹងមូលធន | ៣៩៩,១៧ | ៤០២,០០ |
| អនុបាតគ្របខណ្ឌសន្ទនីយភាព ❶ | ១១៨,៨៣ | ១២៧,៤៦ |
| អនុបាតឥណទានមិនដំណើរការ ❷ | ៤,៦៣ | ៤,៦១ |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ១០៦,២៩ | ១០៥,០៣ |
| **អនុបាតផលចំណេញ(%)** | **ត្រីមាសទី១ឆ្នាំ២០២៣** | **ត្រីមាសទី១ឆ្នាំ២០២២** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (ROA) ❸ | ១,៨៤ | ២,៥៧ |
| អនុបាតចំណេញធៀបនឹងមូលធន (ROE) ❹ | ៩,២០ | ១៤,៣៧ |
| អនុបាតលទ្ធភាពបង់ប្រាក់ | ៦៩៨,៣១ | ៩៦៥,២៦ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | មិនមាន | មិនមាន |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | មិនមាន | មិនមាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | មិនមាន | មិនមាន |

សំគាល់ :

❶: អនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយធនាគារជាតិនៃកម្ពុជា

❷: ឥណទានមិនដំណើរការអនុលោមទៅតាមបទបញ្ញត្តិគណនេយ្យដែលចេញដោយធនាគារជាតិនៃកម្ពុជាចំណាត់ថ្នាក់សំវិធានធន ២០% - ១០០%

❸: អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម : លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ / ទ្រព្យសកម្មសរុប

❹: អនុបាតចំណេញធៀបនឹងមូលធន : លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ / មូលធនសរុប

*) លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទទាបជាងចំណេញ(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ ដោយសារលម្អៀងពីការប្តូររូបិយប័ណ្ណ

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប









# សមាសភាពក្រុមប្រឹក្សាភិបាល



**YIM, Yong Taick**

ប្រធានក្រុមប្រឹក្សាភិបាល



**SIM, Sang Ton**

អភិបាលប្រតិបត្តិ



**Kim, Sung Chul**

អភិបាលប្រតិបត្តិ



**HONG, Jee Soo**

អភិបាលឯករាជ្យ



**LEE, Myunsang**

អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ក្នុងនាមតំណាងឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងក្នុងការបង្ហាញពីលទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ក្នុងឆ្នាំ២០២៣ ដោយអនុវត្តតាមតម្រូវការរបស់ និយ័តករមូលបត្រកម្ពុជា (ន.ម.ក)។

ឆ្នាំ២០២៣ អាចជាឆ្នាំដ៏លំបាកមួយផ្សេងទៀត ទោះបីជាយើងទើបតែរួចផុតពីជំងឺរាតត្បាតកូវីដ-១៩ ក៏ដោយ។ ថ្មីៗនេះ រដ្ឋាភិបាលបានទម្លាក់ការព្យាករណ៍កំណើនសេដ្ឋកិច្ចឆ្នាំ ២០២៣ ពី ៦.៦% ទៅ ៥.៦%។ ទោះបីជាយ៉ាងណាក៏ដោយ ធនាគារ ភ្នំពេញ ពាណិជ្ជ នៅតែបន្តការរីកចម្រើនជាមួយនឹងការរំពឹងទុកខ្ពស់បំផុតចាប់តាំងពីការបើកដំណើរការរបស់យើងក្នុងឆ្នាំ២០០៨។ ជាមួយនឹងការរីកចម្រើនដ៏រឹងមាំដែលយើងសម្រេចបាន និងការកើនឡើងជាបន្តបន្ទាប់នៃចំនួនអតិថិជនដែលបានចាប់ផ្តើមប្រើប្រាស់សេវាកម្មរបស់យើង ផែនការរបស់យើងគឺ បន្តពង្រីកឲ្យកាន់តែទូលំទូលាយនៃវិសាលភាពរបស់យើងទៅកាន់អតិថិជនទូទាំងប្រទេស។ ដើម្បីបង្កើតរឿងដ៏ជោគជ័យនៅអាស៊ីអាគ្នេយ៍ក្នុងវិស័យឧស្សាហកម្មហិរញ្ញវត្ថុដោយការបង្កើតប្រព័ន្ធព័ត៌មានវិទ្យាដែលមានភាពបត់បែនយ៉ាងរហ័ស និងមូលដ្ឋានឌីជីថលនីយកម្មក្នុងផែនការរយៈពេលខ្លី និងក្នុងរយៈពេលមធ្យម ដែលមានសុវត្ថិភាព និងជំរុញការប្រកួតប្រជែងតាមរយៈយុទ្ធសាស្រ្តខុសៗគ្នា ។

យើងនឹងជួយម្ចាស់អាជីវកម្មខ្នាតតូច និងសហគ្រាសធុនតូច និងមធ្យមនៅក្នុងតំបន់ ឱ្យឆ្លងផុតការលំបាកដែលបណ្តាលមកពីជម្ងឺរាតត្បាត កូវីដ-១៩ ខណៈពេលដែលយើងកំពុងពង្រីកផ្នែកហិរញ្ញវត្ថុរបស់យើង។ ហើយកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតនឹងត្រូវបានធ្វើឡើងដើម្បីគាំទ្រដល់សហគមន៍មូលដ្ឋាន និងអ្នកដែលខ្វះខាតផ្សេងទៀត តាមរយៈសកម្មភាពរួមចំណែកជាមួយសង្គម ការធ្វើដូច្នេះវាសម្តែងចេញនូវភាពមានទំនួលខុសត្រូវចំពោះសង្គមរបស់យើងទាំងស្រុង។

ក្នុងនាមតំណាងឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគទុនិកក្រុមប្រឹក្សាភិបាល គណៈប្រតិបត្តិទាំងអស់នៃធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក សម្រាប់ការណែនាំ និងភាពជាអ្នកដឹកនាំ បុគ្គលិករបស់យើងទាំងអស់សម្រាប់ការចូលរួមចំណែក និងការប្តេជ្ញាចិត្តអតិថិជនរបស់យើងទាំងអស់ សម្រាប់ទំនុកចិត្តរបស់ពួកគេមកលើ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក

ជាពិសេស ធនាគារជាតិ នៃ កម្ពុជា (NBC) និងនិយ័តករមូលបត្រកម្ពុជា (SERC) សម្រាប់ដំបូន្មាន និងការគាំទ្រ។

ជាចុងក្រោយ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ជាមួយនឹងការបន្តការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែង ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក នឹងបន្តរីកចម្រើន និងការអនុវត្តល្អបំផុតនៅឆ្នាំ២០២៣ ជាមួយនឹងសមិទ្ធផលនៃគោលដៅផ្សេងបន្ថែមទៀត។

ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣

ហត្ថលេខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក PHNOM PENH COMMERCIAL BANK PLC "PPCBank" ចុះបញ្ជីពាណិជ្ជកម្ម ភ្នំពេញ

YIM. Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

# មាតិកា

**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** ........ 1
**ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប** ........ 2
**សមាសភាពក្រុមប្រឹក្សាភិបាល** ........ 3
**សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល** ........ 4
**ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ** ........ 7
ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ 7
ខ. លក្ខណៈនៃធុរកិច្ច ........ 8
គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ 9
**ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ........ 11
ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក ........ 11
ខ. រចនាសម្ព័ន្ធចំណូល ........ 11
**ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ** ........ 12
**ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ........ 13
ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ 13
ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ 15
គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ 17
ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ 17
ង. ផលប៉ះពាល់អតិផរណា ........ 18
ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល ........ 18
**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក** ........ 18

# ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក** |
| ជាអក្សរឡាតាំង | **Phnom Penh Commercial Bank Plc.** |
| លេខកូដស្តង់ដារ | KH ២០០០១១១A46 |
| ទីស្នាក់ការ | អគារលេខ២១៧ មហាវិថីនរោត្តម<br>សង្កាត់ទន្លេបាសាក់ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | (+៨៥៥) ២៣ ៩០៩ ៩០៩/(+៨៥៥) ២៣ ៩៩៩ ៥០០ |
| គេហទំព័រ | www.ppcbank.com.kh |
| អ៊ីមែល | info@ppcb.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១៥៧៩៤ ចុះថ្ងៃទី២០ មេសា ២០០៨ |
| លេខអាជ្ញាបណ្ណអាជីវកម្ម | B២៣ ចេញដោយធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៦ ធ្នូ ២០១៩ |
| សេចក្តីសម្រេចអនុញ្ញាតិនិងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៩២/២០ គ.ម.ក./ស.ស.រ ចុះថ្ងៃទី០១កញ្ញា ២០២០ |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូល | លោក Lee Jin Young |

## ខ. លក្ខណៈនៃធុរកិច្ច

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានចាប់ផ្ដើមប្រតិបត្តិការធនាគារ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ ដែលមានទីស្នាក់ការកណ្តាលស្ថិតនៅអគារលេខ២១៧ មហាវិថី ព្រះនរោត្តម (ផ្លូវលេខ ៤១) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និងទទួលបានអាជ្ញាបណ្ណពេញលេញជាធនាគារពាណិជ្ជ។ នៅខែកញ្ញា ឆ្នាំ២០១៦ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានស្វាគមន៍សម្រាប់ការចាប់ផ្តើមថ្មីមួយជាមួយភាគទុនិកដ៏រឹងមាំគឺ Jeonbuk Bank Co.. Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co. Ltd.). ក្រុមហ៊ុន Apro Financial Co.. Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន J&K Capital Co.. Ltd. ដែលស្ថិតនៅក្រោម OK Financial Group) និងក្រុមហ៊ុន JB Woori Capital Co.. Ltd (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ JB Financial Group Co.. Ltd.) ដែលមានមូលដ្ឋានស្ថិតនៅប្រទេសកូរ៉េខាងត្បូង។

នៅពេលដែលយើងបន្តកិច្ចខំប្រឹងប្រែងរបស់យើងទៅមុខទៀតយើងក៏មិនភ្លេច និងអបអរសាទរចំពោះភាពជោគជ័យនាពេលកន្លងមក ក្នុងការបំពេញបាននូវតម្រូវការជាច្រើនរបស់អតិថិជនក្នុងផ្នែកសេវាធនាគារ និងខិតខំស្វែងរកវិធីសាស្រ្តនានា ដើម្បីលើកកម្ពស់គុណភាពសេវារបស់យើង គាំទ្រអតិថិជនរបស់យើងទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។ គិតត្រឹមបំណាច់ ត្រីមាសទី១ ឆ្នាំ២០២៣ ទ្រព្យសកម្មសរុបមានចំនួន ១.០០៣ លានដុល្លារអាមេរិក សាខាចំនួន២៣ទូទាំងប្រទេស និងម៉ាស៊ីន ATMs ចំនួន៧០គ្រឿង (ម៉ាស៊ីនATMs ផ្សេងៗទៀតកំពុងត្រូវបានពិចារណានៅទីតាំងសក្តានុពលក្នុងប្រទេសកម្ពុជា)។ បន្ថែមពីនោះ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងបន្តធ្វើការផ្តល់ជូនដល់អតិថិជននូវសេវាដែលមានលក្ខណៈងាយស្រួល និងធ្វើការគាំទ្រដោយបណ្តាញឌីជីថល ដែលធ្វើឲ្យអតិថិជនកាន់តែមានភាពងាយស្រួល ជាមួយនិងបទពិសោធន៍ធនាគារ។ អតិថិជនអាចធ្វើការទំនាក់ទំនងមកយើងតាមរយៈ Live Chat ក្នុងរយៈពេល២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ តាមរយៈបណ្តាញឌីជីថលទាំងអស់របស់ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក។ លើសពីនេះទៅទៀត ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបង្កើតមជ្ឈមណ្ឌលសហគ្រាសធុនតូច-មធ្យម (SME Center) ជាលើកដំបូងរបស់ខ្លួន ដែលនឹងផ្តល់នូវផលិតផល និងសេវាSME។ សហគ្រាសធុនតូច-មធ្យម នឹងត្រូវទទួលបាននូវសេវាពិគ្រោះយោបល់អាជីវកម្មផងដែរ។

ពួកយើងក៏បានពង្រីកនូវការិយាល័យបរទេស (Foreign Desk) មានដូចជា ការិយាល័យកូរ៉េ ជប៉ុន និងចិន ក៏ដូចជា ហ្គោលក្លឹប និងមជ្ឈមណ្ឌល SME ដែលនឹងផ្តល់នូវផលិតផល និងសេវា SME។ ពួកយើងពិតជាផ្តល់តម្លៃដល់អតិថិជនទាំងអស់ និងបន្តធ្វើការអភិវឌ្ឍផលិតផលសេវារបស់ពួកយើង ដើម្បីបម្រើជូនដល់អតិថិជនឲ្យបានល្អបំផុត។

## គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ក្នុងនាមជាធនាគារដែលផ្តោតលើការផ្តល់ភាពងាយស្រួលដល់អតិថិជន យើងតែងតែព្យាយាមក្នុងការពង្រីកបន្ថែមនូវសកម្មភាពប្រតិបត្តិការអាជីវកម្ម និងនាំមកនូវមធ្យោបាយកាន់តែប្រសើរសម្រាប់អតិថិជនដ៏មានតម្លៃរបស់យើង។

ដូច្នេះនៅថ្ងៃទី៩ ខែមករា ឆ្នាំ២០២៣ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានបើកសម្ពោធជាផ្លូវការនូវសាខាពោធិ៍ចិនតុង ដែលបានផ្លាស់ប្តូរទីតាំងពីសាខាទឹកថ្លា បន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា (NBC) នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០២២។

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៣ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានធ្វើសិក្ខាសាលាស្តីពីផែនការអាជីវកម្មឆ្នាំ ២០២៣ ក្នុងគោលបំណងបង្ហាញពីផែនការអាជីវកម្មនិងគោលដៅផ្សេងៗសម្រាប់ឆ្នាំ ២០២៣ ។

នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៣ ការចុះឈ្មោះតាមរយៈអនឡាញ (Online) សម្រាប់ PPCBank KHQR ត្រូវបានដាក់អោយប្រើប្រាស់ជាផ្លូវការ។ PPCBank KHQR គឺជាកម្មវិធីអនឡាញ (Online) ដែលផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការចុះឈ្មោះធ្វើជាពណិជ្ជករដែលអាចធ្វើការទូទាត់តាមរយៈ PPCBank KHQR បាន។

នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ សេវាប្រមូលការទូទាត់វិក័យប័ត្រ ត្រូវបានដាក់នៅលើកម្មវិធីទូរស័ព្ទ (Mobile App). SmartBiz និងតាមសាខាផងដែរ។ សម្រាប់វិក័យប័ត្រទាំងអស់រួមទាំងទឹកភ្លើង និងវិក័យប័ត្រទូទៅ អាចប្រមូល និងធ្វើការទូទាត់តាមរយៈ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ដោយមិនចាំបាច់ធ្វើប្រព័ន្ធអន្តរការជាមួយនឹងប្រព័ន្ធដទៃទៀត ជាមួយនឹងនីតិវិធីងាយស្រួល និងរហ័ស។

នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ កម្មវិធីទូរស័ព្ទ (Mobile App) របស់ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងកម្មវិធី SmartBiz ត្រូវបានធ្វើបច្ចុប្បន្នភាពអោយកាន់តែប្រសើរឡើង និងផ្តល់ភាពងាយស្រួលជាច្រើនទៀត។ សម្រាប់កម្មវិធីទូរស័ព្ទ (Mobile App) អ្នកប្រើប្រាស់គ្រាន់តែបញ្ចូលរូបភាព QR ដើម្បីធ្វើការបង់ប្រាក់។ សម្រាប់ SmartBiz មានមុខងារជូនដំណឹងអំពីការទូទាត់ KHQR (សម្រាប់ទាំងម្ចាស់អាជីវកម្ម និងបុគ្គលិកដើម្បីកំណត់និងទទួលការទូទាត់ដោយ KHQR តាមរយៈ Telegram. SMS. និង App Notification) ក៏ត្រូវបានដាក់បន្ថែមទៅក្នុង Setting Menu ផងដែរ។

នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ កម្មវិធីទូរស័ព្ទ (Mobile App) របស់ធនាគារ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ត្រូវបានកែសម្រួលនីតិវិធីក្នុងការបើកគណនីរហ័ស (Fast Account) និងប្រតិបត្តិការផ្សេងទៀតរួមទាំងការដំណើរការកម្មវិធីទូរស័ព្ទដោយខ្លួនឯង (Self-Subscription) ព្រមទាំងការកំណត់ពាក្យសំងាត់ឡើងវិញ (Reset Password) សម្រាប់ការចូលប្រើប្រាស់ជាលើកដំបូងដើម្បីទទួលបាននូវបទពិសោធន៍ថ្មីៗ និងភាពងាយស្រួល។

# ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានតាមផ្នែក

| លទ្ធផលសម្រេចបានសំខាន់ៗ | ត្រីមាសទី១ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
|---|---|---|
| **ផ្នែកសេវាឥណទាន** | | |
| ចំនួនគណនីឥណទាន | ៩.៣២០ | ៨.៨៣៧ |
| ឥណទានដុលសរុប (លានរៀល) | ៣.២១២.០៥០ | ៣.២០២.៩៨២ |
| **ផ្នែកសេវាប្រាក់បញ្ញើ** | | |
| ចំនួនគណនីប្រាក់បញ្ញើ | ១៥៤.៥១២ | ១៤៨.៣៨០ |
| ប្រាក់បញ្ញើសរុប (លានរៀល) | ២.៩៥៣.៤៦០ | ២.៩៧៤.១៨៣ |
| **ព័ត៌មានទូទៅ** | | |
| ចំនួនសាខាបើកដំណើការ | ២៣ | ២៣ |
| ចំនួនបុគ្គលិកសរុប | ៤៩៣ | ៤៨៥ |
| ចំនួនម៉ាស៊ីន អេធីអឹម | ៧០ | ៧១ |
| ចំនួនម៉ាស៊ីនទូទាត់ | ២១៧ | ២១៥ |

## ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី១ឆ្នាំ២០២៣ | | ត្រីមាសទី១ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន (លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៨១.១៩០ | ៩៥,៥៧ | ៧៦.១៤៣ | ៩៦,៨៦ |
| ២ | ចំណូលកម្រៃ និងជើងសារ | ៣.៧២៤ | ៤,៣៨ | ២.៤៤៥ | ៣,១១ |
| ៣ | ចំណូលផ្សេងៗ | ៤៣ | ០,០៥ | ២២ | ០,០៣ |
| **ចំណូលសរុប** | | **៨៤.៩៥៦** | **១០០** | **៧៨.៦១០** | **១០០** |

# ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមមើលឧបសម្ពន្ធរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ។

# ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងវិភាគខាងក្រោមផ្តោតលើលទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារ ភ្នំពេញពាណិជ្ជ ម.ក (PPCBank)និងក្រុមហ៊ុនបុត្រសម្ព័ន្ធ J&A (Cambodia) Investment Co.. Ltd គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ ដែលត្រូវបានត្រួតពិនិត្យដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុរួមត្រូវបានរៀបចំស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ហ.អ.ក) និងអនុលោមទៅតាមបទបញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍ណែនាំផ្សេងៗដែលចេញដោយធនាគារជាតិនៃកម្ពុជា។

## ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ធនាគារភ្នំពេញពាណិជ្ជ ម.ក មានប្រភពចំណូលចំនួន៣ធំៗគឺ ចំណូលការប្រាក់ ចំណូលពីកម្រៃ និងជើងសារនិងចំណូលផ្សេងៗ។

- ចំណូលការប្រាក់រួមមាន ចំណូលការប្រាក់ពីការផ្តល់ឥណទាន ចំណូលការប្រាក់ពីការដាក់ប្រាក់បញ្ញើរនៅធនាគារ និងចំណូលការប្រាក់បានមកពីមូលបត្រវិនិយោគនានា។
- ចំណូលកម្រៃ និងជើងសាររួមមាន កម្រៃសេវាឥណទាន ចំណូលពីការផ្ទេរប្រាក់ក្នុងស្រុក និងបរទេស ចំណូលពីសេវាប្រាក់បញ្ញើ ចំណូលពីសេវាធានា និង ចំណូលពីប័ណ្ណផ្សេងៗ។
- ចំណូលផ្សេងៗ រួមមាន ចំណូលពីអត្រាប្តូរប្រាក់លើការវិនិយោគ និងចំណូលផ្សេងៗទៀត។

### ២. ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល | ត្រីមាសទី១ឆ្នាំ២០២៣ | | ត្រីមាសទី១ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ចំនួន (លានរៀល) | ភាគរយ (%) | ចំនួន(លានរៀល) | ភាគរយ (%) |
| ១ | ចំណូលពីការប្រាក់ | ៨១.១៩០ | ៩៥,៥៧ | ៧៦.១៤៣ | ៩៦,៨៦ |
| ២ | ចំណូលកម្រៃ និងជើងសារ | ៣.៧២៤ | ៤,៣៨ | ២.៤៤៥ | ៣,១១ |
| ៣ | ចំណូលផ្សេងៗ | ៤៣ | ០,០៥ | ២២ | ០,០៣ |
| ចំណូលសរុប | | ៨៤.៩៥៦ | ១០០ | ៧៨.៦១០ | ១០០ |

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ទទួលបានចំណូលភាគច្រើនមកពីការប្រាក់ ដែលមាន ៩៦% នៃប្រាក់ចំណូលសរុបក្នុងត្រីមាសទី១ ឆ្នាំ២០២៣។

## ៣. ការវិភាគគម្លាតចំណេញដុល

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានរៀបចំរបាយការណ៍លទ្ធផលរួមរបស់ខ្លួនក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីប្រាក់ចំណេញដុល ប៉ុន្តែទម្រង់របាយការណ៍នេះអាចបង្ហាញលើចំណេញការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់ដែលនឹងត្រូវយកមកពិភាក្សានៅក្នុងចំណុចបន្ទាប់ការវិភាគចំណេញ(ខាត) មុនបង់ពន្ធ។

## ៤. ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ

| សង្ខេបនៃរបាយការន៍ចំនេញខាត | ត្រីមាសទី១ ឆ្នាំ២០២៣ (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២២ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ចំណូលពីការប្រាក់ | ៨១.១៩០ | ៧៦.១៤៣ | ៥.០៤៧ | ៦,៦៣ |
| ចំណាយលើការប្រាក់ | (៣៣.៧០៦) | (២៣.៨១៣) | (៩.៨៩៣) | ៤១,៥៥ |
| **ចំណូលមកពីការប្រាក់សុទ្ធ** | ៤៧.៤៨៤ | ៥២.៣៣០ | (៤.៨៤៦) | (៩,២៦) |
| ចំណូលកម្រៃ និងជើងសារ | ៣.៧២៤ | ២.៤៤៥ | ១.២៧៨ | ៥២,២៨ |
| ចំណាយកម្រៃ និងជើងសារ | (១.០៩០) | (៩៤៥) | (១៤៥) | ១៥,៣០ |
| **ចំណូលកម្រៃនិងជើងសារសុទ្ធ** | ២.៦៣៤ | ១.៥០០ | ១.១៣៤ | ៧៥,៥៧ |
| ចំណូលប្រតិបត្តិការផ្សេងៗ | ៤៣ | ២២ | ២១ | ៩៦,៣៦ |
| ចំណាយបុគ្គលិក | (៨.៨៥២) | (៦.៧៦៥) | (២.០៨៧) | ៣០,៨៥ |
| ចំណាយប្រតិបត្តិការ | (៤.០៤៨) | (៣.៩៥៩) | (៨៩) | ២,២៦ |
| ចំណាយរំលស់ | (៦.៣១២) | (៦.៧៧០) | ៤៥៨ | (៦,៧៧) |
| **ប្រាក់ចំណេញពីប្រតិបត្តិការ** | ៣០.៩៤៩ | ៣៦.៣៥៩ | (៥.៤១០) | (១៤,៨៨) |
| ការខាតបង់លើឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ | (៣.៨៧១) | (១.៦៨២) | (២.១៨៩) | ១៣០,១៤ |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | ២៧.០៧៨ | ៣៤.៦៧៧ | (៧.៥៩៩) | (២១,៩១) |

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ប្រាក់ចំណេញមុនបង់ពន្ធមានចំនួន ២៧.០៧៨លានរៀល (២២% តិចជាងប្រៀបធៀបទៅនឹងត្រីមាសទី១ ឆ្នាំ២០២២) ។ ការថយចុះនៃប្រាក់ចំណេញគឺដោយសារការកើនឡើងនៃចំណាយការប្រាក់ និងការកើនឡើងនៃចំណាយប្រតិបត្តិការ។

## ៥. ការវិភាគចំណេញ (ខាត) ក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ត្រីមាសទី១ ឆ្នាំ២០២៣ (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២២ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ២៧.០៧៨ | ៣៤.៦៧៧ | (៧.៥៩៩) | (២១,៩១) |
| ចំណាយពន្ធលើប្រាក់ចំណូល | (៥.៨៥៣) | (៦.៩៣៨) | ១.០៨៥ | (១៥,៦៥) |
| **ប្រាក់ចំណេញសុទ្ធក្នុងគ្រា** | **២១.២២៦** | **២៧.៧៣៩** | **(៦.៥១៣)** | **(២៣,៤៨)** |

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធមានចំនួន ២១.២២៦លានរៀល ដែលបានថយចុះ ២៣% ប្រៀបធៀបទៅនឹងត្រីមាសទី១ ឆ្នាំ២០២២ ការថយចុះនេះមកពីការប្រែលប្រួលដូចបានបកស្រាយក្នុងចំនុច៤ (ការវិភាគចំណេញ (ខាត) មុនបង់ពន្ធ)។

## ៦. ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| សង្ខេបនៃរបាយការណ៍ចំណេញខាត | ត្រីមាសទី១ ឆ្នាំ២០២៣ (លានរៀល) | ត្រីមាសទី១ ឆ្នាំ២០២២ (លានរៀល) | គម្លាត (លានរៀល) | គម្លាត (ភាគរយ) |
|---|---|---|---|---|
| ប្រាក់ចំណេញសុទ្ធក្នុងគ្រា | ២១.២២៦ | ២៧.៧៣៩ | (៦.៥១៣) | (២៣,៤៨) |
| ការខាតលម្អិតផ្សេងៗ | (២.៧៤៧) | (១.៨១៣) | (៩៣៤) | ៥១,៥៤ |
| **ប្រាក់ចំណេញលម្អិតសរុប** | ១៨.៤៧៨ | ២៥.៩២៦ | (៧.៤៤៨) | (២៨,៧៣) |

## ៧. ការវិភាគកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិញ្ញវត្ថុ

ផលប៉ះពាល់សេដ្ឋកិច្ចនៃជម្លោះ រវាងប្រទេសរុស្ស៊ី និងអ៊ុយក្រែន ចាប់ផ្ដើមនាឆ្នាំ២០២២ ការដាក់ទណ្ឌកម្មសេដ្ឋកិច្ចជាបន្តបន្ទាប់ដោយបានកំណត់គោលដៅនៃផ្នែកធំៗលើ សេដ្ឋកិច្ចប្រទេសរុស្ស៊ី មន្ត្រីរាជការរុស្ស៊ី និងសមាជិកនៃរដ្ឋាភិបាលប្រទេសរុស្ស៊ី។ ទាំងជម្លោះ និងការដាក់ទណ្ឌកម្មបានជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក ក្នុងអំឡុងពេលនៃវិបត្តិកូវីដ-១៩។ រួមទាំងការដួលរលំរបស់ធនាគារអាមេរិកនាពេលថ្មីៗនេះបានធ្វើឱ្យទីផ្សារមានភាពវឹកវរបណ្ដាលឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងលើស្ថាប័នហិរញ្ញវត្ថុដែលទន់ខ្សោយ ដែលកំពុងតស៊ូជាមួយនឹងផលវិបាកនៃការកើនឡើងអត្រាការប្រាក់ និងអត្រាអតិផរណាដ៏ខ្ពស់។ ដូច្នេះ សកម្មភាពរបស់ធនាគារអាចនឹងមានផលប៉ះពាល់ខ្លះៗ មកលើប្រតិបត្តិការហិរញ្ញវត្ថុ និងកម្រិតនៃប្រាក់ចំណេញរបស់ធនាគារ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

កង្វះខ្សែសង្វាក់ផ្គត់ផ្គង់គឺជាកង្វល់ដ៏ធំមួយក្នុងអំឡុងពេលនៃការកើនឡើងនៃអតិផរណាខ្ពស់ បញ្ហានេះនាំឲ្យកង្វះខាតតាមផ្នែកនៃផលិតផល ឬផលិតផលទាំងស្រុង ដែលបង្កើតអតុល្យភាពក្នុងការផ្គត់ផ្គង់ និងតម្រូវការ ហើយបានជម្រុញឱ្យតម្លៃកើនឡើង។ ជាមួយនឹងស្ថានភាពបែបនេះ ដូច្នេះ ផលិតផល និងសេវាកម្មថ្មីៗត្រូវបានបន្ថែម ដើម្បីរក្សាបាននូវកម្រិតនៃប្រាក់ចំណេញ និងកំណើនរបស់ធនាគារ។ ខាងក្រោមនេះគឺជាផលិតផល និងសេវាកម្មថ្មីៗដែលបានបន្ថែម៖

- ការចុះឈ្មោះតាមរយៈអនឡាញ (Online) សម្រាប់ PPCBank KHQR ត្រូវបានដាក់អោយប្រើប្រាស់ជាផ្លូវការ។ PPCBank KHQR គឺជាកម្មវិធីអនឡាញ (Online) ដែលផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការចុះឈ្មោះធ្វើជាពាណិជ្ជករដែលអាចធ្វើការទូទាត់ តាមរយៈ PPCBank KHQR បាន។
- សេវាប្រមូលការទូទាត់វិក័យប័ត្រ ត្រូវបានដាក់នៅលើកម្មវិធីទូរស័ព្ទ (Mobile App). SmartBiz និងតាមសាខាផងដែរ។ សម្រាប់វិក័យប័ត្រទាំងអស់រួមទាំង ទឹកភ្លើង និងវិក័យប័ត្រទូទៅ អាចប្រមូល និងធ្វើការទូទាត់តាមរយៈ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ដោយមិនចាំបាច់ធ្វើប្រព័ន្ធអន្តរការជាមួយនឹងប្រព័ន្ធដទៃទៀត ជាមួយនឹងនីតិវិធីងាយស្រួល និងរហ័ស។
- កម្មវិធីទូរស័ព្ទ (Mobile App) របស់ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងកម្មវិធី SmartBiz ត្រូវបានធ្វើបច្ចុប្បន្នភាពអោយកាន់តែប្រសើរឡើង និងផ្តល់ភាពងាយស្រួលជាច្រើនទៀត។ សម្រាប់កម្មវិធីទូរស័ព្ទ (Mobile App) អ្នកប្រើប្រាស់គ្រាន់តែបញ្ចូលរូបភាព QR ដើម្បីធ្វើការបង់ប្រាក់។ សម្រាប់ SmartBiz មានមុខងារជូនដំណឹងអំពីការទូទាត់ KHQR (សម្រាប់ទាំងម្ចាស់អាជីវកម្ម និងបុគ្គលិកដើម្បីកំណត់និងទទួលការទូទាត់ដោយ KHQR តាមរយៈ Telegram. SMS. និង App Notification) ក៏ត្រូវបានដាក់បន្ថែមទៅក្នុង Setting Menu ផងដែរ។
- កម្មវិធីទូរស័ព្ទ (Mobile App) របស់ធនាគារ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក ត្រូវបានកែសម្រួលនីតិវិធីក្នុងការបើកគណនីរហ័ស (Fast Account) និងប្រតិបត្តិការផ្សេងទៀត រួមទាំងការដំណើរការកម្មវិធីទូរស័ព្ទដោយខ្លួនឯង (Self-Subscription) ព្រមទាំងការកំណត់

ពាក្យសំងាត់ឡើងវិញ (Reset Password) សម្រាប់ការចូលប្រើប្រាស់ជាលើកដំបូង ដើម្បីទទួលបាននូវបទពិសោធន៍ថ្មីៗ និងភាពងាយស្រួល។

**២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម**

ការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនមានផលប៉ះពាល់ដល់ធនាគារឡើយ ។

**៣. ការវិភាគលើពន្ធ**

ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនត្រូវមានកាតព្វកិច្ចបង់ពន្ធដូចបានកំណត់ក្នុងបទប្បញ្ញត្តិស្តីពីពន្ធដាររបស់ព្រះរាជាណាចក្រកម្ពុជា។

ជាមួយនឹងកាតព្វកិច្ចពន្ធ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក បានទទួលវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ "**មាស**" ពីអគ្គនាយដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ ២០២២ និង២០២៣។

**៤. ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ**

សេដ្ឋកិច្ចពិភពលោកកំពុងមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ ចំពេលពីការកើនឡើងនៃអតិផរណា អាចនឹងមានផលប៉ះពាល់ខ្លះដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក មានការថយចុះនៃចំណូលដែលមានចំណូលការប្រាក់សុទ្ធសរុប ៤៧.៤៨៤លានរៀល ដែលស្មើនឹងការថយចុះ ៩.៣% ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២២។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ស្ថានភាពចំហនៃរូបិយប័ណ្ណបរទេស ត្រូវបានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ជាប្រចាំតាមបទបញ្ញាត្តិ ដើម្បីអាចវាស់វែង និងធានាថាវានឹងមិនធ្វើឲ្យប៉ះពាល់ដល់និរន្តរភាពនៃប្រាក់ចំណេញរបស់ធនាគារ។

ពាក់ព័ន្ធនឹងអត្រាការប្រាក់ធនាគារកំណត់អត្រាការប្រាក់ថេរសម្រាប់ប្រាក់បញ្ញើរ និងប្រាក់កម្ចីរបស់ខ្លួនសម្រាប់ប្រតិបត្តិការអាជីវកម្ម។ ដូច្នេះធនាគារមិនមានទទួលរងហានិភ័យជាសារវន្តទាក់ទងនឹងអត្រាការប្រាក់មកលើលទ្ធផលនៃប្រតិបត្តិការអាជីវកម្មធនាគារនោះទេ ។

ឥទ្ធិពលនៃថ្លៃទំនិញ មិនមានផលប៉ះពាល់មកលើលទ្ធផលប្រតិបត្តិរបស់ធនាគារឡើយ ។

## ង. ផលប៉ះពាល់អតិផរណា

ជាមួយអត្រាអតិផរណាបច្ចុប្បន្ន នឹងមិនមានផលប៉ះពាល់ណាមួយជាសារវន្តមកលើលទ្ធផលប្រតិបត្តិការអាជីវកម្មរបស់ធនាគារនៅឡើយទេ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល

យោងតាមរបាយការណ៍ប្រចាំឆ្នាំ ២០២២ របស់ធនាគារជាតិនៃកម្ពុជា ធនាគារជាតិនៃកម្ពុជានឹងអនុវត្តគោលនយោបាយរូបិយវត្ថុដូចខាងក្រោម៖

- គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឲ្យស្ថិតក្នុងកម្រិតសមស្រប
- រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីចូលរួមរក្សាស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជន
- លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមយន្តការទីផ្សារ
- អភិវឌ្ឍឧបករណ៍នយោបាយរូបិយវត្ថុថ្មីៗ និង
- ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពនយោបាយរូបិយវត្ថុ។

**ហត្ថលេខាអភិបាលរបស់ធនាគារភ្នំពេញពាណិជ្ជ ម.ក**

ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣

បានអាន និងឯកភាព

លោក YIM. Yong Taick

ប្រធានក្រុមប្រឹក្សាភិបាល

PPCBank